# គុកវាំង

គុកវាំង មានទីតាំងស្ថិតនៅខាងកើតទីប្រជុំជនតាំងក្រសាំងប្រមាណ ៨០០ម៉ែត្រ និងស្ថិតនៅក្នុងបរិវេណវត្តមួយឈ្មោះថា "វត្តពោធិវាំង" ក្នុងភូមិវាំងត្បូង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ។ ឈ្មោះ "គុកវាំង" មានរំលេចនៅក្នុងរឿងព្រេងដែលនិទានអំពី "ភ្នំសន្ទុក" ដែលនិទានមកថា "កាលពីព្រេងនាយនៅស្រុកសន្ទុក ខេត្តកំពង់ធំ មានស្ដេចមួយអង្គ ទ្រង់មានព្រះអគ្គមហេសី ព្រះរាជបុត្រ ស្រីស្នំក្រមការ សេនាទាហាន និងនាហ្មឺនសព្វមុខមន្ត្រីជាច្រើនស្ដេចទ្រង់បានចេញព្រះរាជបញ្ជាឲ្យឆ្មាវព្រៃមួយកន្លែង សង់ប្រាសាទ និងគុក ភូមិប្រាសាទរហូតមកទល់សព្វថ្ងៃ។ លុះបានសង់ប្រាសាទនោះហើយ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យឆ្មាវព្រៃមួយកន្លែងទៀត ពាយព្យប្រាសាទនោះ ធ្វើជាទីសម្រាប់ស្រីស្នំ មានកំពែងជុំវិញ ហើយទីនោះក៏ជាប់មានឈ្មោះថា "ភូមិវាំង" រហូតមកទល់សព្វថ្ងៃ"។ រឿងព្រេងមួយនេះ ស្ដាប់ទៅអាចទាក់ទងនឹងឈ្មោះ "គុកវាំង" បានខ្លះៗ។ ប៉ុន្តែ អ្វីដែលគួរសម្គាល់នោះគឺ តើហេតុដូចម្ដេចបានជាអ្នកស្រុកហៅប្រាសាទនេះថា "គុកវាំង"? ពាក្យ "**គុក**" គឺជាពាក្យដែលអ្នកស្រាវជ្រាវស្គាល់ជាទូទៅដែលសំដៅលើ "ប្រាសាទ"។ ដោយឡែកពាក្យ "**វាំង**" អាចមានន័យពីរយ៉ាង ដែលន័យទីមួយអាចមានថ្នាក់ពាក្យជាកិរិយាសព្ទដែលមានន័យថា "**បាំង**" ហើយត្រូវនឹងពាក្យខ្មែរបុរាណថា "**បង៑**" ដូចមានចារឹកនៅក្នុងសិលាចារឹកព្រះធាតុរកា K.155, សិលាចារឹកកំពែងយ៉ៃ (ស្រុកសៀមសព្វថ្ងៃ) K.374។[១] ន័យទីពីរ ពាក្យ "**វាំង**" អាចមានន័យជានាមថា "**កំពែង**" ដែលត្រូវនឹងពាក្យខ្មែរបុរាណ "**កំវេង៑**" ដូចមានចារឹកនៅក្នុងសិលាចារឹកជាច្រើនដូចជា សិលាចារឹកក្ដីស្ដី (ព្រៃវែង) K.760, សិលាចារឹកស្រង៉ែ (សៀមរាប) K.933, សិលាចារឹកស្ដុកកក់ធំ (ស្រះកែវ សៀមសព្វថ្ងៃ) K.235, សិលាចារឹកក្ដីអង្គ (ព្រៃវែង) K.56។[២] ដូច្នេះហើយ ការដែលគេហៅថា "គុកវាំង" ទំនងមកពីនៅជុំវិញប្រាសាទមានកំពែងព័ទ្ធជុំវិញ ឬអាចសំដៅលើប្រាសាទដែលស្ថិតនៅភូមិវាំង។ ក្នុងនេះដែរ "គុកវាំង" មានន័យថា "គុកដាក់មនុស្សនៅក្នុងព្រះបរមរាជវាំង" តាមការរៀបរាប់ដូចរឿងព្រេងខាងលើ ទំនងមិនត្រឹមត្រូវឡើយ។

កន្លងមក ការស្រាវជ្រាវនៅប្រាសាទនេះមានតិចតួចខ្លាំងណាស់។ ក្នុងនោះ មានលោក Henri Parmentier បានសិក្សាក្រាស់ក្រែលជាងគេនៅឆ្នាំ១៩១៣ និង១៩២៧។ ក្រោយមក លោក

---

[១] Saveros Pou 1992: 292.

[២] Saveros Pou 1992: 91.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

AMS
អរិយធម៌ខ្មែរ

Jean Boisselier គ្រាន់តែបានបញ្ជាក់តិចតួចប៉ុណ្ណោះ។ ក្រោយមកទៀត ឆ្នាំ២០០៨ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយសាលាបារាំងចុងបូព៌ាប្រទេស ក៏បានចុះបញ្ជីប្រាសាទមួយនេះដែរ ដោយបានរៀបរាប់សង្ខេបអំពីរចនាសម្ព័ន្ធទូទៅ។

គុករាំង សាងសង់ឡើងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ បែរមុខទៅទិសខាងកើត ហើយជញ្ជាំងផ្សេងទៀតគេលម្អជាទ្វារបញ្ឆោត (រូបលេខ១-៣)។ ទ្វារនីមួយៗ គេរៀបឥដ្ឋដូចជាបន្ទះត្រង់នៅចំកណ្ដាល ហើយអមដោយសសរផ្អោបនិងហោជាងនៅខាងលើ។ ហោជាងនៅទិសខាងកើតផ្នែកកណ្ដាលមានលម្អដោយក្បាច់រាងដូចជាកូនវិមានអណ្ដែត[៣] (រូបលេខ២) និងមានចម្លាក់គូឱ[៤] (រូបលេខ៥) ដែលស្ថិតក្នុងទម្រង់សិល្បៈរចនាបថកំពង់ព្រះ ស.វ.ទី៨ និងមានលក្ខណៈស្រដៀងប្រាសាទភូមិប្រាសាទដែលស្ថិតនៅមិនឆ្ងាយពីគុករាំងដែរ។ ចំណែក ផ្តែរទ្វារ មានការរលុបផ្នែកកណ្ដាលស្ទើរតែទាំងអស់ ប៉ុន្តែយើងអាចនៅមើលឃើញចម្លាក់សត្វមករនៅខាងចុងផ្តែរ ដែលចម្លាក់សត្វមករនេះបែរមុខចេញមកក្រៅ ហើយនៅផ្នែកខាងលើយើងឃើញចង្វាយក្បាច់អង្គរឆ្លាស់តម្រៀបគ្នា (រូបលេខ៦)។[៥] ផ្តែរទ្វារនេះ យើងឃើញនៅផ្នែកខាងចុងមានស្នាមកាត់ចោលខ្លះដែលយើងអាចសន្និដ្ឋានបានថា ផ្តែរនេះទំនងមិនមែនជាផ្តែរដើមកាលពីសាងសង់ប្រាសាទនៅដំណាក់កាលដំបូងឡើយ។ ក្បាច់លម្អរបស់ផ្តែរ មានទម្រង់ដូចសិល្បៈចុងរចនាបថគូលែន និងដើមរចនាបថព្រះគោ ដើមស.វ.ទី៩ ដ្បិតយើងឃើញចម្លាក់សត្វមករមានលក្ខណៈស្រដៀងខ្លាំងជាមួយផ្តែរទ្វារប្រាសាទត្រពាំងផុងនៅខេត្តសៀមរាប។

***តើផ្តែរទ្វារនេះទំនងលើកដាក់នៅសម័យណា?***

ប្រសិនយើងឱ្យអាយុកាលរបស់ផ្តែរនៅរាងដើមស.វ.ទី៩ ដូច្នោះយើងក៏អាចដឹងច្បាស់ថាផ្តែរនេះប្រាកដជាលើកដាក់ក្រោយដើមស.វ.ទី៩ ព្រោះគេអាចយកផ្តែរនេះមកពីទីណាផ្សេងមកកាត់តម្រឹមដាក់នៅលើប្រាសាទដែលសាងសង់ឡើងតាំងពីស.វ.ទី៨។

នៅខាងមុខប្រាសាទ យើងឃើញទ្រនាប់ជណ្ដើរមួយដែលធ្វើអំពីថ្មភក់ មានរាងដូចត្របកឈូកដែលអាចមានអាយុកាលនៅសម័យមុនអង្គរ (ស.វ.ទី៧-៨)[៦] ហើយជាភស្តុតាងមួយសម្រាប់បញ្ជាក់អាយុកាលរបស់ប្រាសាទ ប៉ុន្តែភស្តុតាងនេះមិនអាចបញ្ជាក់ពីកាលបរិច្ឆេទនៃការលើកផ្តែរ

---

[៣] Parmentier 1927: 356

[៤] Bénisti 1970: 15

[៥] Boisselier 1966: 158

[៦] ជន ច័ន្ទណារ័ត្ន ២០១៨: ១៦-២៥។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បានឡើយ (រូបលេខ២៧)។ អ្វីដែលគួរកត់សម្គាល់ជាតឹកតាងសំខាន់នោះ គឺនៅក្បែរប្រាសាទមានជើងទម្រមួយដែលគេឆ្លាក់ដោយថ្មមួយដុំភ្ជាប់គ្នាបានជាជើងទម្រ និងមានស្នាកស្នាមចម្លាក់គ្រុឌចំពាក់កណ្ដាលជើងទម្រនោះ ដែលអាចឱ្យយើងសន្និដ្ឋានបានថា ជើងទម្រនេះអាចស្ថិតនៅក្នុងរចនាបថកោះកេរ ស.វ.ទី១០ (រូបលេខ២៨)។[៧] តឹកតាងនេះ នាំឱ្យយើងដឹងថា នៅស.វ.ទី១០ គុករាំងទំនងមានការជួសជុល និងកែប្រែបន្ថែមឡើងវិញនៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (គ.ស.៩២៨-៩៤១) ហើយលក្ខណ:បែបនេះ យើងធ្លាប់ឃើញមាននៅប្រាសាទអំពិលរលំដែលជាប្រាសាទស.វ.ទី៨ និងកែប្រែបន្ថែមនៅស.វ.ទី១០ ដូចប្រាសាទគុករាំងដែរ។ ម៉្លោះហើយ ការកែប្រែនៅស.វ.ទី១០នេះហើយដែលប្រហែលជាពេលគេលើកផ្ដែរទ្វារនេះដាក់នៅលើប្រាសាទ។ លើសពីនេះ នៅក្នុងអត្ថបទរបស់លោក Henri Parmentier បានរៀបរាប់ថា សសរពេជ្រនៅគុករាំងមានរាងប្រាំជ្រុង នេះក៏អាចជាតឹកតាងបញ្ជាក់អំពីសកម្មភាពមនុស្សនៅសម័យអង្គរដូចគ្នា ដ្បិតសសរពេជ្រសម័យអង្គរច្រើនមានរាងប្រាំបីជ្រុង ប៉ុន្តែសព្វថ្ងៃសសរពេជ្រនេះបានបាត់បង់ពីទីតាំងដើមទៅហើយ។[៨]

ជារួមមក គុករាំង ទំនងជាប្រាសាទដែលចាប់ផ្ដើមសាងសង់ឡើងនៅដើមស.វ.ទី៨ ក្នុងរចនាបថកំពង់ព្រះ ហើយទំនងសាងបន្ថែមនៅស.វ.ទី១០ ក្នុងរចនាបថកោះកេរ រាជ្យព្រះបាទជ័យវរ្ម័នទី៤ (គ.ស.៩២៨-៩៤១) ហើយចំណែកផ្ដែរទ្វារវិញ គឺជាផ្ដែរទ្វារចាស់នៅស.វ.ទី៩ ដែលទំនងគេយកមកពីទីតាំងណាមួយមកកាត់តម្រឹមលើកដាក់នៅលើប្រាសាទក្នុងរវាងស.វ.ទី១០។

---

[៧] ហុក ស្រីល័ក្ខណា ២០១៦: ៣៣-៣៥។

[៨] Parmentier 1927: 182.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ គុកវាំង (មើលពីទិសខាងកើត)



រូបលេខ២៖ គុកវាំង (មើលពីទិសនិរតី)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ គុកវាំង (មើលពីទិសខាងលិច)



រូបលេខ៤៖ វិមានអណ្ដែត នៅមុខខាងកើត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ចម្លាក់គូឃុ នៅមុខខាងកើត



រូបលេខ២៦៖ ផ្តែរទ្វារ នៅមុខខាងកើត



រូបលេខ៧៖ ទ្រនាប់ជណ្ដើរ នៅមុខខាងកើត



រូបលេខ៨៖ បំណែកជើងទម្រមានស្នាកស្នាមរូបគ្រុឌ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# ឯកសារយោង


## ជន ច័ន្ទណារ័ត្ន

២០១៨, *ការវិវត្តទ្រនាប់ជណ្ដើរនៅក្នុងសិល្បៈខ្មែរ*, ភ្នំពេញ

## ហុក ស្រីល័ក្ខណា

២០១៦, *ការវិវត្តជើងទម្រក្នុងសិល្បៈខ្មែរ*, ភ្នំពេញ

**Bénisti, Mireille**

1970, *“Rapports  entre le premier art Khmer et l’art Indien”* EFEO, Tome I-II, Paris

**Boisselier, Jean**

1966, “*Asie du Sud-Est, Le Cambodge* ”, Tome I, Paris

**Parmentier, Henri**

1927, *“L’Art Khmér Primitif”*, Tome I, Paris

**Saveros Pou**

1992, *Dictionnaire Vieux Khmer-Français-Englais*, Paris


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION